# ការសម្ភាសន៍របស់បងប្រុស(ប្តី)ឱនសំអាតនិងបងស្រី(ប្រពន្ធ)ថុង យៀត

កៈ អ្នកសម្ភាសន៍គេមាន រត្ន ពិសី ខៈ អ្នកដែរគេត្រូវសម្ភាសន៍ (ប្តី)ឱន សំអាតនិង (ប្រពន្ធ)ថុង យៀត

**ការសម្ភាសន៍ជីវប្រវត្តិសង្ខេបរបស់បងប្រុស(ប្តី)ឱន សំអាតនិង បងស្រី(ប្រពន្ធ)ថុង យៀត**

ការសម្ភាសន៍ជីវប្រវត្តិសង្ខេបរបស់បងប្រុស(ប្តី)មានឈ្មោះថា ឱន សំអាតហើយនិងបងស្រី(ប្រពន្ធ)ថុន យៀត ហើយពួកគាត់ទាំងពីរនាក់មានការតស៊ូជាមួយគ្នាតាំងពីបាតដៃទទេហើយគាត់បានកសាងជាគ្រួសារមួយដ៏មានសុភមង្គលហើយនិងមានការសប្បាយរីករាយនៅក្នុងគ្រួសាររបស់គាត់ហើយបងប្រុសជាមេគ្រួសារហើយគាត់ចេះស្តាប់សំដីរបស់អ្នកនៅក្នុងគ្រួសាររបស់គាត់ហើយចំណែកបងស្រីគាត់បានតស៊ូហើយគាតត្រូវចិញ្ចឹមម្តាយចាស់នៅផ្ទះហើយគាត់ត្រូវរកប្រាក់ចំនូលនិងទៅគ្រួសារទៀត។ហើយបងប្រុសនិងបងស្រីគាត់មានការតស៊ូហើយមានការជួបឧបសគ្គជាច្រើននៅក្នុងជីវិតរបស់គាត់ហើយគាត់មិនបានធ្លាប់ឆ្លងកាតនៅសម័យប្រល័យពូជសាសន៍នោះទេតែគាត់បានដឹងនៅរឿងមួយនេះបានខ្លះពីការរៀនហើយពីម្តាយរបស់គាត់ដែលគាត់បានប្រាប់ហើយឲ្យគាត់បានដឹងថានៅសម័យមួយនោះវាមានការលំបាកយ៉ាងណាទើបបានដល់សព្វថ្ងៃនេះ។ពួកគាត់ទាំងពីរជាមនុស្សដែរស្រឡាញ់អ្នកជិតខាងហើយចេះរាបអានអ្នកជិតខាងនិងចេះឲ្យតម្លៃមនុស្សនិងមានការប្រឹងប្រែងនៅក្នុងជីវិតរបស់គាត់ដោយមានការលំបាកយ៉ាងណាក៏គាត់មិនគិតទៅផ្លូវអាក្រក់ឡើយ។ធ្វើឡើងនៅភូមិខ្ពប ឃុំកោះឧកញ៉ាតី ស្រុកខ្សាច់កណ្តាល កណ្តាល ធ្វើឡើងនៅថ្ងៃទី០១ ខែ ០៦ ឆ្នាំ ២០១៨។

កៈ ជាដំបូងខ្ញុំសូមជំរាប់សួរបងខ្ញុំបាទមានឈ្មោះថា រត្ន ពិសី ហើយខ្ញុំធ្វើឲ្យសាកលវិទ្យាល័យមួយដែរមានឈ្មោះថាសាកលវិទ្យាល័យ BYU ដែរមានទីតាំងនៅអាមេរិចណាបង។

ខៈ បាទ!

កៈ ហើយដើម្បីថែរក្សាជីវប្រវត្តិរបស់បងហើយនិងដើម្បីថែរក្សាជីវប្រវត្តិរបស់ជីដូនជីតារបស់បងហើយដើម្បីទុកឲ្យកូនចៅជំនាន់ក្រោយរបស់បងថាបងមានការលំបាកហើយឲ្យគាត់បានស្តាប់ថាបងជាអ្នកជំនាន់មុនមានការជួបឧបសគ្គជាច្រើនហើយនៅក្នុងជីវិតរបស់បងអញ្ចឹងបង។

ខៈ បាទ!

កៈ ហើយអញ្ជឹងខ្ញុំធ្វើឡើងនៅថ្ងៃទី ០១ ខែ ០៦ ឆ្នាំ ២០១៨។ហើយអញ្ចឹងអត់ទោសបងមានឈ្មោះអីគេដែរបង?

ខៈ ខ្ញុំមានឈ្មោះ ឌិន សំអាត។

កៈ បាទ! បងមានឈ្មោះថា ឌិន សំអាត។

ខៈ បាទ! ឌិន សំអាត។

កៈ បាទ! ហើយអញ្ជឹងសព្វថ្ងៃនិងបងមានអាយុប៉ុន្មានហើយបង?

ខៈ ហើយខ្ញុំមានអាយុ៣៧ហើយ។

កៈ បាទ! ហើយអញ្ជឹងអាយុ៣៧ហើយបង។

ខៈ បាទ!

កៈ ហើយអញ្ចឹងបងមានឈ្មោះហៅក្រៅទេបង?

ខៈ អត់មានឈ្មោះហៅក្រៅទេ។

កៈ បាទ! អត់មានទេបង។

ខៈ បាទ!

កៈ ហើយអញ្ចឹងបងមានចាំថ្ងៃខែកំណើតរបស់បងទេបង?

ខៈ អត់ចាំផងនិង។

កៈ បាទ! ហើយអញ្ជឹងបងមានដឹងថាបងកើតឆ្នាំណាទេបង?

ខៈ អត់ចាំផងនិងហើយទាល់តែខ្ញុំទៅមើលអត្តសញ្ញាណប័ណ។

កៈ បាទ! ហើយអញ្ជឹបងកើតនៅថ្ងៃណាដែរបង?

ខៈ ខ្ញុំកើតនៅថ្ងៃទី ០១  ខែ ០២ ឆ្នាំ១៩៨៥។

កៈ បាទ! ហើយអញ្ចឹងបងកើតនៅថ្ងៃទី០១ ខែ០២ ឆ្នាំ១៩៨៥បង។ហើយអញ្ជឹងបងមានចាំថាបងមានឆ្នាំខ្មែរយើងបងមានឆ្នាំអីបង?

ខៈ បាទ!

ក៖ បាទ! ដូចឆ្នាំខ្មែរយើងដូច ជូត ឆ្លូវ ខាល ថោះអីបងមានចាំទេ?

ខ៖ ខ្ញុំឆ្នាំ កោ។

ក៖ បាទ! ហើយអញ្ចឹងបងឆ្នាំ កោបង?

ខ៖ បាទ!

ក៖ ហើយអញ្ចឹងបងមានចាំកន្លែងកំណើតរបស់បងទេបង?

ខ៖ ទីកន្លែងកំណើតនិងនៅកោះឧកញ៉ាតីនិងម៉ង។

ក៖ បាទ! ហើយអញ្ចឹងបងអ្នកនៅកោះនិងម៉ងបង?

ខ៖ បាទ!

ក៖ ហើយអញ្ចឹងបងនៅភូមិអីគេដែរបង?

ខ៖ ខ្ញុំនៅភូមិខ្ពប ឃុំកោះឧកញ៉ាតី។

ក៖ បាទ! ហើយអញ្ចឹងបងនៅកោះឧកញ៉ាតីនិង។

ខ៖ បាទ!

ក៖ បាទ! ហើយអញ្ចឹងនៅនិងគេហៅភូមិខ្ពប ឃុំកោះឧកញ៉ាតី ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាលបង?

ខ៖ បាទ!

ក៖ បាទ! ហើយអញ្ចឹងបងមានបងប្អូនប៉ុន្មាននាក់ដែរបង?

ខ៖ ខ្ញុំមានបងប្អូនប្រាំមួយនាក់។

ក៖ បាទ! ហើយអញ្ចឹងបងមានបងប្អូនបង្កើតប្រាំមួយនាក់បង។

ខ៖ បាទ!

ក៖ ហើយអញ្ចឹងបងជាកូនទីប៉ុន្មានដែរបង?

ខ៖ ខ្ញុំជាកូនទី៣។

ក៖ បាទ!ហើយអញ្ចឹងបងជាកូនទី៣បង?

ខ៖ បាទ!

ក៖ ហើយអញ្ចឹងបងមានចាំឈ្មោះបងប្អូនរបស់បងទាំងអស់ទេបង?

ខ៖ ខ្ញុំចាំតា។

ក៖ បាទ! ហើយអញ្ចឹងទីមួយមានឈ្មោះអីគេដែរបង?

ខ៖ ទីមួយមានឈ្មោះថា ឌិន កុសល ។

ក៖ បាទ! ឌិន កុសល។ហើយអញ្ចឹងទីពីរមានឈ្មោះអីគេដែរបង?

ខ៖ ឌិន ចាន់ធឿន។

ក៖ បាទ! ឌិន ចាន់ធឿន។ហើយទៅបងហើយអញ្ចឹងទីបួនបង?

ខ៖ ឌិន សុខា។

ក៖ បាទ! ហើយអញ្ចឹងឌិន សុខាហើយអញ្ចឹងទីប្រាំមានឈ្មោះអីដែរបង?

ខ៖ ឌិន សុខខេន។

ក៖ បាទ! ហើយអញ្ចឹងទីប្រាំមួយមានឈ្មោះអីដែរបង?

ខ៖ ឌិន ចាន់ថា។

ក៖ បាទ! ហើយទៅឌិន ចាន់ថា។ហើយអញ្ចឹងបងមានចាំសាច់រឿងជាមួយពួកគាត់ទេបង?

ខ៖ អត់ចាំទេ។

ក៖ បាទ!
ហើយអញ្ចឹងបងអត់ចាំទេបង។ហើយអញ្ចឹងអត់ថាបងធ្លាប់ទៅណាជាមួយគ្នាអញ្ចឹងអត់ចាំទេបង។

ខ៖ អត់ផងនិង។

ក៖ ហើយអញ្ចឹងបងអត់ចាំទេ។ហើយអញ្ចឹងបងមានចាំថាចូលចិត្តធ្វើអីជាមួយពួកគាត់ទេ?

ខ៖
អត់ដែរអត់ដែរមានអីរវីរវល់អីជាមួយគាត់ផងនិង។អត់ដែរទៅណាជាមួយគ្នាទេហើយធ្វើការនៅបែកពីគ្នា។

កៈ បាទ!ពួកគាត់នៅរៀនទាំងអស់គាត់មានគ្រួសារអស់ហើយបង?

ខៈ គេមានគ្រួសារអស់ហើយនិង។ហើយនៅតែអាពៅម្នាក់និង។

កៈ បាទ! ហើយនៅសល់ពៅម្នាក់ហើយគាត់នៅជាមួយបងឬគាត់នៅជាមួយឪពុកម្តាយ។

ខៈ វានៅជាមួយម៉ែខ្ញុំនិង។

កៈ គាត់នៅជាមួយម្តាយបងហើយអញ្ចឹងផ្ទះបងនៅណាដែរបង?

ខៈ ខ្ញុំនៅនិងម៉ង។

កៈ បាទ! ផ្ទះបងនៅនិងម៉ងបង?

ខៈ បាទ!

កៈ ហើយគាត់នៅរៀនតាបងអី?

ខៈ បើអាពៅនិងវាឈប់រៀនហើយនិង។

កៈ បាទ! គាត់ឈប់រៀនហើយបង។

ខៈ បាទ!

កៈ ហើយអញ្ចឹងគាត់នៅធ្វើអីដែរបង?

ខៈ វានៅមើលគោជាមួយពុកខ្ញុំនិង។

កៈ បាទ! គាត់នៅជាមួយឪពុករបស់បង។

ខៈ បាទ!

កៈ បាទ! ហើយអញ្ចឹងបងមានចាំឈ្មោះឪពុកម្តាយរបស់បងផ្ទាល់ទេបង?

ខៈ ខ្ញុំចាំតា។

កៈ ហើយអញ្ចឹងលោកឪពុកមានឈ្មោះអីដែរបង?

ខៈ គាត់មានឈ្មោះថាយ៉ែម ឌិន ។

កៈ បាទ! គាត់មានឈ្មោះថា យ៉ែម ឌិន
។ហើយអញ្ចឹងអ្នកម្តាយបងវិញមានឈ្មោះអីដែរបង?

ខ៖ ម្ដាយខ្ញុំមានឈ្មោះថា ហឺរ វ៉ុន ។

ក៖ បាទ! គាត់មានឈ្មោះថា ហឺរ វ៉ុន ។

ខ៖ បាទ!

ក៖ ហើយអញ្ចឹងបងមាននៅចាំថាគាត់មានប្រជុនប៉ុន្មានហើយឥឡូវនឹងបង?

ខ៖ អត់ចាំដែរនិង។

ក៖ បាទ! ហើយអញ្ចឹងលោកឪពុកនៅអត់ចាំដែរបង?

ខ៖ បាទ! ខ្ញុំអត់ចាំ។

ក៖ បាទ! ហើយអញ្ចឹងលោកឪពុកគាត់មានប្រជុនរស់ឬគាត់បានចែកឋានទៅហើយបង?

ខ៖ នៅទាំងពីរនិង។

ក៖ បាទ! ហើយអញ្ចឹងគាត់នៅមានប្រជុនរស់ទេ។តែអត់ដឹងថាគាត់មានប្រជុនប៉ុន្មានទេ។

ខ៖ បាទ!អត់ដឹងទេ។

ក៖ ហើយអញ្ចឹងបងមានដែរដឹងថាគាត់កើតឆ្នាំណាខែណាទេ?

ខ៖ អត់ដឹងដែរនិង។

ក៖ បាទ! បងអត់ដឹងដែរហើយអញ្ចឹងឆ្នាំខ្មែរយើងនិងបងមានចាំទេ?

ខ៖ ហើយឪពុកនិងឆ្នាំអីហើយយាយឆ្នាំអីព្រោះអីពួកគាត់និងឆុងគ្នានិងប្រហែលឆ្នាំម្សាញ។

ក៖ បាទ! ហើយអញ្ចឹងអ្នកម្ដាយឆ្នាំម្សាញ។

ខ៖ មិនមែនទេឪពុកឆ្នាំម្សាញ។

ក៖ បាទ! ហើយអញ្ចឹងអ្នកម្ដាយមានឆ្នាំអីគេដែរបង?

ខ៖ អត់ចាំទេ។

ក៖ ហើយអញ្ចឹងបងអត់ចាំទេ។

ខ៖ បាទ!

កៈ ហើយអញ្ចឹងបងមានចាំថាគាត់កើតនៅទីណាទេបង?

ខៈ ហើយបើពុកខ្ញុំគាត់នៅនិងម៉ង។

កៈ បាទ! ហើយអញ្ចឹងអ្នកម្ដាយវិញ?

ខៈ បើម្ដាយខ្ញុំគាត់នៅខាងព្រៃអំពិល។

កៈ បាទ! គាត់នៅខាងព្រៃអំពិល។ហើយអញ្ចឹងគាត់នៅខាងនោះវិញបង?

ខៈ ហើយគាត់នៅខាងក្រោយម្ខាង។

កៈ បាទ! ហើយអញ្ចឹងគាត់នៅខាងក្រោយម្ខាងវិញ។ហើយអញ្ចឹងស្នេហាឆ្លងទឹកហើយនិង។

ខៈ បាទ!

កៈ ហើយអញ្ចឹងបងមានចាំថាគាត់ប្រកបមុខរបរអីដើម្បីចិញ្ចឹមបង?

ខៈ បាទ! ឪពុកម្ដាយខ្ញុំគាត់ធ្វើកសិករនិង។

កៈ បាទ! ហើយគាត់ជាអ្នកធ្វើស្រែធ្វើចំការបងណោះ។

ខៈ បាទ!

កៈ ហើយអញ្ចឹងអ្នកម្ដាយធ្វើស្រែចំការដែរ?

ខៈ បាទ!

កៈ ហើយអញ្ចឹងបងតាមបងគិតថាគាត់ជាមនុស្សបែបណាដែរដូចជាគាត់មានលក្ខណៈដូចគាត់កាចឬក៏គាត់ស្លូតអញ្ចឹងណាស់?

ខៈ បាទ!បើថាគាត់ស្លូតហើយថាគាត់កាចថាបានដែរហើយគាត់អត់សូវរករឿងកូនអញ្ចឹងណាស់។

កៈ ហើយអញ្ចឹងគាត់មានដែរវាយកូនទេបង?

ខៈ គាត់វាយតាពីតូចនិង។

កៈ បាទ! គាត់វាយដៃរបងហើយកាលពីបងនៅតូចបានខូចដៃរបង។

ខៈ កាលនិងខ្ញុំទៅលេងទឹកជាមួយបងខ្ញុំ។

កៈ បាទ! ហើយអញ្ចឹងបងទៅលេងទឹកជាមួយបងហើយអញ្ចឹងទៅគាត់មកឃើញទៅហើយគាត់វាយទៅ។

ខៈ បាទ! គាត់វាយ។

កៈ ហើយមកបងឯងខូចពេកនិងហើយ។

ខៈ បាទ! បើកាលនិងទឹកឡើងនិង។

កៈ បាទ! ហើយអញ្ចឹងគាត់មានការជំលោះជាមួយអ្នកក្នុងភូមិអីទេបង?

ខៈ អត់សូវផងនិង។

កៈ បាទ!អត់មានទេបង។

ខៈ បាទ!

កៈ ហើយអញ្ចឹងអ្នកម្ដាយក៏គាត់អញ្ចឹងដែរហើយគាត់កាចទេបង?

ខៈ បើម៉ែអត់សូវកាចទេ។

កៈ បាទ! អត់សូវកាចទេបង?

ខៈ បាទ!

កៈ ហើយអញ្ចឹងបងមានចាំសាច់រឿងជាមួយឪពុកម្ដាយបងទេថាពេលដែរបងមានការលំបាកជាមួយគាត់ហើយធ្លាប់អត់ស៊ីអត់ឃ្លានជាមួយគាត់បងមានចាំទេបង?

ខៈ ខ្ញុំអត់មានសាច់រឿងអីជាមួយគាត់ផងនិងពេលព្រឹកឡើងខ្ញុំទៅធ្វើការបាតៗអញ្ចឹងណាស់ហើយអញ្ចឹងអត់មានសាច់រឿងអីជាមួយគាត់ផងនិង។

កៈ បាទ! តាំងពីក្មេងមកបងហើយបងមានចាំទេបង?

ខៈ អត់សូវចាំដែរនិង។គ្មានអីក្រៅពីធ្វើស្រែធ្វើចំការនិង។

កៈ បាទ!

ខៈ បាទ!
ហើយតែប្រលឹងឡើងខ្ញុំក្រោបទៅបើកឡានដឹកដីគេបាត់ៗហើយខ្ញុំក្រោបតាំងពីម៉ោង៤ទៅ
។

កៈ បាទ! ហើយអញ្ចឹងបងអ្នកបើកឡានដឹកដីគេបង?

ខៈ បាទ! ហើយខ្ញុំពីមុនបរទោសសេះពីមុននិង។

កៈ បាទ! ហើយអញ្ចឹងបងពីមុនបងបរទោសសេះបង?

ខៈ បាទ! ហើយខ្ញុំក្រោបតាំងពីម៉ោង៤និង។

កៈ បាទ!

ខៈ ហើយកាលនិងខ្ញុំបានរៀនត្រឹមបានថ្នាក់ទី៤ទី៥និង។

កៈ បាទ! ហើយនិងបងបានចេះអានអក្សរអីដែរបង?

ខៈ បាទ!

កៈ ហើយអញ្ចឹងបងបើកឡានឲ្យគេហើយបងបើកឡានអាត្រាកឬបើកឡានដឹកដីបង?

ខៈ អត់ទេខ្ញុំធ្វើខាងគ្រូឡានគេនិង។

កៈ បាទ! ហើយអញ្ចឹងបងគ្រូឡានគេបង។

ខៈ បាទ! ធ្វើគ្រូឡាន។

កៈ បាទ! គ្រូឡានគេ។

ខៈ ហើយខ្ញុំចេះបើកតែយើងអត់ទាន់មានពាក់មីអញ្ចឹងណាស់។

កៈ បាទ! អត់ទាន់មានពាក់មីបង។

ខៈ បាទ!

កៈ
ហើយអញ្ចឹងបងគាត់មានដែរបានប្រាប់ថាគាត់មានជីវិតរបស់គាត់កាលគាត់នៅពីក្មេងទេប
ង?

ខ៖ អត់ផងនិង។

ក៖ បាទ! ហើយគាត់អត់បានប្រាប់បងថាគាត់នៅពីក្មេងគាត់មានការលំបាកអីខ្លះទេបង?

ខ៖ បាទ! គាត់អត់ដែរបានប្រាប់ខ្ញុំផងនិង។

ក៖ គាត់អត់ដែរប្រាប់បងទេបង។ហើយអញ្ចឹងគាត់អត់ដែរដឹងពីគាត់ខ្លះៗទេបង?

ខ៖ បាទ! ខ្ញុំអត់ដែរដឹងពីគាត់ផងនិង។

ក៖ បាទ! ហើយអញ្ចឹងបងមានដែរចាំឈ្មោះជីដូនជីតាខាងឪពុកខាងម្ដាយរបស់បងទេបង?

ខ៖ អត់សូវចាំទេព្រោះអីចាស់ៗគាត់បាត់បង់យូរហើយនិង។

ក៖ បាទ! អត់ចាំទេបងណោះ។

ខ៖ បាទ!

ក៖ ហើយអញ្ចឹងក្រុមគ្រួសារបងជាអ្នកខេត្តកណ្ដាលនិងទាំងអស់គ្នា?

ខ៖ បាទ!

ក៖ ហើយតាំងពីកើតមកបងណោស។

ខ៖ បាទ! ខ្ញុំនៅនិងតាំងពីកើតមកម៉េះ។

ក៖ ហើយអញ្ចឹងបងមានបង
ប្អូនបង្កើតហើយបងប្អូនជីដូនមួយដែរមាននៅស្រុកគេទេដូចជានៅអាមេរិច កាណាដា អូស្រ្តាលីមានអត់បង?

ខ៖ អត់មានទេ។

ក៖ បាទ! ហើយអញ្ចឹងសព្វថ្ងៃនិងអត់មានដែរ?

ខ៖ បាទ! អត់មានផងនិង។

ក៖ បាទ! ហើយខាងជីដូនមួយមានអត់បង?

ខ៖ អត់មានទាំងអស់និង។

ក៖ បាទ! ហើយអញ្ចឹងបងមានគ្រួសារហើយតាបង?

ខ៖ មានហើយនោះប្រពន្ធខ្ញុំ។

ក៖ បាទ! ហើយអញ្ចឹងបងបងស្រីគេមានឈ្មោះអីគេដែរបង?

ខ៖ ថុង យៀត ។

ក៖ បាទ! គាត់មានឈ្មោះថា ថុង យៀតនិងបង។

ខ៖ បាទ!

ក៖ ហើយបងមានខាងក្រៅមានឈ្មោះអីដែរបង?

ប្រពន្ធ៖ មានឈ្មោះថា ថុង យៀតនិង។

ក៖ បាទ! ហើយមិញនិងខ្ញុំគាត់ហៅ ប៉ោង ។

ប្រពន្ធ៖ ពេលនិងខ្ញុំមានកូនហើយគាត់ចេះតែហៅខ្ញុំប៉ោងទៅនិង។

ក៖ បាទ! ហើយអញ្ចឹងឃើញបងស្រីពោះធំគាត់ចេះតែប៉ោងៗទៅបង?

ប្រពន្ធ៖ ចា៎!

ក៖ ហើយអញ្ចឹងបងការនៅនិងម៉ងបង?

ខ៖ បាទ!ការនៅនិង។

ក៖ បាទ! ហើយអញ្ចឹងការនៅឆ្នាំណាដែរបង?

ប្រពន្ធ៖ ខ្ញុំការនិងឆ្នាំ ២០០៩ ។

ក៖ បាទ! ហើយអញ្ចឹងបងការនៅឆ្នាំ ២០០៩បងណោះ។

ប្រពន្ធ៖ ចា៎!

ក៖ ហើយអញ្ចឹងថ្ងៃខែបងមានចាំទេបង?

ប្រពន្ធ៖ ខ្ញុំការនៅថ្ងៃទី២៦ ខែ ០៥។

ក៖ បាទ! ហើយអញ្ចឹងបងការនៅថ្ងៃទី ២៦ ខែ ០៥បងណោះ។

ប្រពន្ធ៖ ចា៎! បើឆ្នាំខ្ញុំការឆ្នាំ ជូត។

កៈ បាទ! បងការនៅឆ្នាំ ជូតបងណោះ។

ប្រពន្ធៈ ចាំ!

កៈ
ហើយអញ្ចឹងបងពេលដៃរការនិងឪពុកម្តាយបងជាអ្នករៀបចំឲ្យឬបងឃើញគ្នាស្រឡាញ់គ្នាបង?

ប្រពន្ធៈ ខ្ញុំស្រឡាញ់គ្នានិង។

កៈ បាទ! ហើយអញ្ចឹងបងស្រឡាញ់គ្នាបង។

ប្រពន្ធៈ នឹងហើយ។

កៈ ហើយបងឃើញគ្នាហើយស្រឡាញ់គ្នាទៅ។

ប្រពន្ធៈ ដូចគ្នានៅស្រុកភូមិជាមួយគ្នានិងណាស់។

កៈ បាទ! កាលពីដំបូងនិងបងកើតអីបានស្គាល់គ្នាបងស្រី។

ប្រពន្ធៈ ដូចគាត់ធ្លាប់ចេញចូលនៅនិងអីអញ្ចឹងណាស់។

កៈ បាទ!
ហើយគាត់មកលេងសើចនៅនិងទៅ។ហើយអញ្ចឹងបងមានដៃរធ្លាប់រៀនជាមួយគ្នាទេបង?

ប្រពន្ធៈ អត់ដៃរធ្លាប់រៀនជាមួយគ្នាផងនិង។

កៈ បាទ! អត់ដៃររៀនជាមួយគ្នាផងនិង។

ប្រពន្ធៈ គ្រាន់តែគាត់និងបងខ្ញុំច្រើនអញ្ចឹងណាស់។

កៈ បាទ !គាត់បងបងស្រីច្រើនបង។

ប្រពន្ធៈ ចាំ!

កៈ ហើយអញ្ចឹងគាត់បងប៉ុន្មានឆ្នាំដៃរបង?

ប្រពន្ធៈ គាត់បងខ្ញុំ៧ឆ្នាំ។

កៈ បាទ! គាត់បងបងស្រី៧ឆ្នាំបង។

ប្រពន្ធ៖ ចា៎!

ក៖ បង៦ទៅ៧ឆ្នាំច្រើនដែរបង។

ប្រពន្ធ៖ ពេលខ្ញុំការនិងខ្ញុំមានអាយុ១៩ឆ្នាំហើយគាត់មានអាយុ២៦ឆ្នាំ។

ក៖ បាទ! ហើយបងធ្លាប់ដើរលេងជាមួយគ្នាទៅបង?

ខ៖
អត់ដែរនិងដើរលេងជាមួយគ្នាផងនិងតែស្រឡាញ់គ្នាតែអត់ដែរបានដើរលេងអីជាមួយគ្នាផងនិង។

ក៖ បាទ! អត់ដែរបង។

ប្រពន្ធ៖ ហើយដែរដូចឥឡូវគេស្រឡាញ់គ្នាគេដើរលេងជាមួយគ្នាអីអញ្ចឹងណាស់។

ក៖ បាទ!

ប្រពន្ធ៖ អត់ដែរទេគាត់ដើរមកលេងហើយខ្ញុំអង្គុយត្បាញអញ្ចឹងទៅណាស់។

ក៖ បាទ!

ប្រពន្ធ៖ ហើយខ្ញុំអង្គុយត្បាញអញ្ចឹងទៅហើយគាត់មកលេងផ្ទះខ្ញុំធម្មតាអញ្ចឹងទៅណាស់។

ក៖ ហើយអញ្ចឹងមកលេងផ្ទះបងមែនបង?

ប្រពន្ធ៖ នឹងហើយ។

ក៖ បាទ !ហើយអញ្ចឹងបងប្រុសខូចដែរបងមកលេងផ្ទះគេបង?

ប្រពន្ធ៖ ចា៎!

ក៖ អត់ដឹងថាកូនស្រីគេក្រមុំនិង។

ប្រពន្ធ៖ គាត់មកលេងធម្មតានិងហើយគាត់មកជាមួយមិត្តភក្តិគាត់អញ្ចឹងទៅ។

ក៖ បាទ! ហើយគាត់មកឃើញបងស្រីអញ្ចឹងទៅ។

ប្រពន្ធ៖
នឹងហើយ។ហើយគ្រាន់តែមានបុណ្យទានអីនៅវត្តអញ្ចឹងនាំគ្នាដើរទៅទាំងរ៉ូង១អញ្ចឹងទៅណាស់ហើយនាំគ្នាទៅទាំងអស់គ្នានិងហើយបើឲ្យទៅដូចឥឡូវនិងអត់ទេ។

កៈ បាទ! អត់ទេ។

ប្រពន្ធៈ ហើយដូចក្មេងឥឡូវនិងអត់មានទេ។

កៈ បាទ!

ប្រពន្ធៈ ចាំ! ហើយយើងស្រឡាញ់គ្នាអញ្ចឹងបើមកលេងអីអត់ប្រព្រឹត្តិអីទេហើយបើមកលេងៗត្រង់ៗអញ្ចឹងទៅណាស់ហើយបើឲ្យដើរលេងដូចគ្នាឥឡូវនិងអត់ទេ។

កៈ បាទ! ហើយអញ្ចឹងដូចថាពេលនិងគាត់ជូនជំនូនបងប៉ុន្មានដែរបង?

ប្រពន្ធៈ ហើយកាលណុងតិចដែរនិង១០០០ដាងនិង។

កៈ បាទ! បាន១០០០ដាងបង។

ប្រពន្ធៈ ហើយកាលណុង១០០០ប៉ុន្មានទេ១៥០០អញ្ចឹងហើយកាលណុង។

កៈ បាទ!បាន១៥០០កាលនិងបង។ហើយកាលពីដំបូងហើយបងបានជូននិងបងប្រុសបងមានបានធ្លាប់ជួនគ្នាពីមុនមកទេបង?

ប្រពន្ធៈ អត់ដែរផងនិង។

កៈ បាទ! ដូចបងប្រុសគាត់មកមើលបងទៅ?

ប្រពន្ធៈ នឹងហើយដូចថាមកអញ្ចឹងមកលេងផ្ទះពួកម៉ាក់អញ្ចឹងទៅហើយអញ្ចឹងស្គាល់គ្នាធម្មតាអញ្ចឹងទៅ។

កៈ បាទ!

ខៈ ហើយអញ្ចឹងទៅដូចថាស្រឡាញ់អញ្ចឹងទៅហើយគាត់ឲ្យម្ដាយគាត់ចូលមកស្ដីដណ្ដឹងនិងទៅ។

កៈ បាទ!

ប្រពន្ធៈ ហើយដូចថាយើងស្រឡាញ់គ្នាហើយបើណាត់គ្នាទៅដើរលេងអីនិងខ្ញុំអត់ដែរទេ។

ក៖ បាទ! អត់ទេបង។

ប្រពន្ធ៖ អត់ទេហើយគាត់មានចិត្តហើយគាត់មែនអ្នកដើរលេង។

ក៖ បាទ!

ប្រពន្ធ៖
ហើយដូចថាគាត់មានបក្សពួកដើរលេងអីអត់មានទេហើយយើងស្គាល់គាត់ដូចអ្នកក្នុងស្រុកបើអ្នកឆ្ងាយស្រុកយើងមើលចិត្តវាមិនឃើញអ្នកនៅក្នុងស្រុកយើងមើលចិត្តដឹងថាគេអត់ខូតអត់ខើល។

ក៖ បាទ!

ប្រពន្ធ៖
គាត់រាល់ថ្ងៃនឹងស្រាក៏មិនផឹកបារីក៏គាត់មិនដែលជក់ដែលនិយាយទៅមួយចប់គាត់នៅផ្ទះចឹងគាត់ទំនេរពីការងារគាត់ជួយកិច្ចការផ្ទះដូចជាដាំបាយធ្វើម្ហូបញ្ញុំាអីចឹងទៅ។

ក៖ បាទ!គាត់ល្អដែលអ្នកមីងបានស្វាមីល្អណាស់?

ប្រពន្ធ៖ ចាំ!នឹងហើយគាត់មិនចេះខូតខើលទេ។

ក៖ បាទ!មួយជីវិត្តនឹងមិចមានអីក៏បានដែលតែសំខាន់គឺសុភមង្គនៅក្នុងគ្រួសារល្អហើយ។

ប្រពន្ធ៖ ចាំ!តែគ្រាន់តែយើងរាល់ថ្ងៃនឹងយើងនៅអត់។

ក៖ បាទ!អត់ៗទៅអោយតានៅក្នុងគ្រួសារយើងមានសុភមង្គ។

ប្រពន្ធ៖
ចាំ!នៅក្នុងគ្រួសារខ្ញុំអត់អីទេគាត់មិនដែលអោយយើងពិបាកចិត្តដូចថាពិបាកចិត្តគាត់ទៅមានស្រីញីអីអត់មានទេបើរឿងនឹងខ្ញុំអត់ភ័យម៉ង?

ក៖ បាទ!ក្រែងគាត់ផឹកស៊ីមករករឿងយើងចឹងណាស់?

ប្រពន្ធ៖
ផឹកស៊ីមករករឿងយើងគាត់អត់ដែលទេនិយាយរួមទៅគឺអត់ដែលតាំងពីការមកជាង១០ឆ្នាំមិនដែលគាត់ទៅផឹកស៊ីហើយមកឈ្លោះគ្នាដូចថាយើងឈ្លោះយើងមានហើយនៅក្នុងគ្រួសារយើងណាស់តែគ្រាន់ថាមានតែយើងទេសំដីលូយទៅគេតែបើគេវិញអត់ដែលមានតែគាត់ដូចចង់និយាយថាយើងនិយាយទៅគាត់សុខចិត្តដើចេញទៅផ្ទះម៉ែគាត់ទៅដូចថាយើង

ឈប់ខឹងចឹងគាត់មកវិញចឹងគាត់ហៅរកយើងធម្មតាទេបើគេអត់រឿងគេក៏គេមិនដែររករឿងយើងដែរនិង។

ក៖ បាទ! ត្រូវហើយបងបើយើងមិនរករឿងគេក៏គេមិនរករឿងយើងដែរបងស្រី?

ប្រពន្ធ៖ ចាំ! តែរាល់ថ្ងៃនិងសរសើរដែរបានប្តីអត់រករឿងអត់ផឹកស៊ីហើយពិបាកបក្សពួកអីទេបើប្រាក់ខែក៏អត់បាត់ដែរ។

ក៖ បាទ!

ប្រពន្ធ៖ ចាំ! គាត់បានប្រាក់ខែ១៥០ទៅ១៦០គាត់ឲ្យយើង។

ក៖ បាទ!

ប្រពន្ធ៖ ហើយខ្ញុំឲ្យគេទុកថា៥០ដុល្លាហើយមនុស្សប្រុសតែងតែមានលុយជាប់កាប៉ៅណាស់។

ក៖ បាទ! បងស្រីត្រូវហើយបង។

ប្រពន្ធ៖ ហើយគាត់ឲ្យយើង១០០ផ្គប់ផ្គង់គ្រួសារទៅ។

ក៖ បាទ!

ប្រពន្ធ៖ ហើយបើប្រាក់ខែគាត់ទុកគ្រាន់ជាសាហុយទៅមកអីអញ្ចឹងទៅចេះមានទុកនៅក្នុងខ្លួនហើយ។

ក៖ បាទ!

ប្រពន្ធ៖ ហើយយើងក៏គោសរុកយកគេទាំងអស់ដែរ។
ក៖ បាទ!

ប្រពន្ធ៖ ហើយគ្រាន់តែយើង។

ក៖ បាទ! យើងចេះយល់គ្នាបងស្រី។

ប្រពន្ធ៖ ចាំ! នឹងហើយយើងចេះយល់គ្នាហើយដូចថាយើងមានកូនឈឺអីអញ្ចឹងទៅគេមានលុយហើយគេជួយចេញមើលកូនទៀតទៅ។

កៈ បាទ!

ប្រពន្ធៈ ហើយយើងនិយាយទៅគ្រួសារយើងដឹងចិត្តគ្នាហើយយើងមានអាយុច្រើនៗដែរ។

កៈ បាទ!

ប្រពន្ធៈ
ហើយមិនដូចថាក្មេងឥឡូវវាស្រឡាញ់គ្នាហើយយើងមិនថាមិចទេពេលខ្លះវាភ្លឹតភ្លើនវាស្រឡាញ់គ្នាយកគ្នាបានមួយឆាវអញ្ចឹងទៅណាស់ហើយឲ្យម្ដាយការបានបំពេញមុខអញ្ចឹងណាស់។

កៈ បាទ!

ប្រពន្ធៈ
ហើយដល់ពេលហើយការបានប៉ុន្មានបែកបាក់គ្នានិងហើយបើយើងចាស់ចិត្តចេះគិតនិងហើយយើងមានអាយុច្រើនដែរអញ្ចឹងណាស់។

កៈ បាទ!

ប្រពន្ធៈ ហើយដល់ពេលយើងមានការគិតវែង។

កៈ បាទ!

ប្រពន្ធៈ
ហើយក្មេងឥឡូវនិងគេគិតរឿងសប្បាយហើយគេគិតរឿងថាហើយគ្រួសារខ្ញុំនិយាយត្រង់ហើយចឹងឲ្យគេថាបងឯងមានអនុស្សាវរីយ៍អីជាមួយគ្រួសារហើយទម្រមអត់ដែរគេដើរលេងអីអត់ដែរទេ។ហើយដូចមានការទំនេរអីនិងនៅផ្ទះនិងហើយពេលខ្លះធ្វើម្ហូបជាមួយគ្រួសារនិងទៅ។

កៈ បាទ! ហើយអញ្ចឹងបានថាគ្រួសារមានសុភមង្គលអញ្ចឹងបងស្រី។

ប្រពន្ធៈ ចាំ! ហើយបើដូចគេនិងវាដូចជាគ្មាននិង។

កៈ បាទ! អត់មានទេបងស្រី?

ប្រពន្ធៈ ចាំ!

ក៖ ហើយអញ្ចឹងបងបើនិយាយពីភាសាខ្មែរយើងនិងបងមានការចេះភាសាខ្មែរច្រើនទេបងស្រី?

ប្រពន្ធ៖ ខ្ញុំចេះច្រើន។

ក៖ បាទ! ហើយអញ្ចឹងបងបានរៀនថ្នាក់ទីប៉ុន្មានដែរបងស្រី?

ប្រពន្ធ៖ ខ្ញុំហេសខ្ញុំថ្នាក់ទីប្រាំមួយនិង។

ក៖ បាទ! ហើយអញ្ចឹងបងស្រីបានរៀនថ្នាក់ទីប្រាំមួយប៉ុណ្ណឹងបានដែរ។ហើយអញ្ចឹងបានមានចាំថាសាលាបងនៅណាទេបង?

ប្រពន្ធ៖ បើនិយាយពីសាលាខ្ញុំនៅក្បាលកោះនិង។

ក៖ បាទ! នៅក្បាលកោះនិង។

ប្រពន្ធ៖ ចាំ!

ក៖ បាទ! នៅវត្តក្បាលកោះយើងនិង។ហើយអញ្ចឹងបងមានចាំថាសាលានិងមានឈ្មោះអីគេដែរបងស្រី?

ប្រពន្ធ៖ សាលាខ្ញុំមានឈ្មោះថាសាលាបឋមសិក្សាក្បាលកោះ។

ក៖ បាទ! ហើយអញ្ចឹងក្បាលកោះអញ្ចឹងម៉ងបង។

ប្រពន្ធ៖ ចាំ!

ក៖ ហើយអញ្ចឹងពេលនិងបងមានមិត្តភក្តីជិតស្និតប៉ុន្មាននាក់ដែរបងស្រី?

ប្រពន្ធ៖ ខ្ញុំមានមិត្តភក្តិជិតស្និតច្រើន។

ក៖ បាទ! កាលនិងបងមានមិត្តភក្តីជិតស្និតច្រើនបងស្រី។

ប្រពន្ធ៖ ព្រោះអីថាមានមិត្តភក្តីជិតស្និតបើយើងនិយាយទៅពេលយើងរៀននិងជាអ្នករៀនពូកែហើយដល់ពេលហើយគ្នាយើងរៀនអត់សូវចេះអញ្ចឹងណាស់យើងនាំគ្នាបាន

ហើយចេះតែលួចយកព្រីសយ៉ុងឲ្យគ្នាអញ្ចឹងណាស់ហើយស្គាល់គ្នាហើយរាប់គ្នាទាល់តែឥឡូវនិងណាស់។

កៈ បាទ!

ប្រពន្ធៈ ហើយគេចេះតែហៅទៅព្រោះគេឥឡូវនិងគេមានៗ។

កៈ បាទ!

ប្រពន្ធៈ ហើយដូចគេថាអញ្ចឹងមែនតែម្ដាយឪពុកគេតស៊ូបានរៀនបានច្រើនអញ្ចឹងណាស់។

កៈ បាទ!

ប្រពន្ធៈ ហើយដល់ឥឡូវគេបានរៀនបានច្រើនៗណាស់។

កៈ បាទ!

ប្រពន្ធៈ
ហើយខ្លះគេរៀនបានពេទ្យម្នាក់មួយធ្វើពេទ្យនៅតាមផ្លូវវត្តនិងគេធ្វើពេទ្យនៅនិងតា។

កៈ បាទ!

ប្រពន្ធៈ ហើយគេពីរនាក់បងប្អូនគេធ្វើពេទ្យទាំងនិងណាស់។

កៈ បាទ! តែគេនៅរាប់អានបងតាអីបងស្រី?

ប្រពន្ធៈ គេនៅរាប់អានគ្នាធម្មតានិង។

កៈ បាទ! គេអត់មានរើសអើងអីទេបងស្រី?

ប្រពន្ធៈ គេចេះតែមានហើយព្រោះអីគេមានជាងយើងអញ្ចឹងណាស់។

កៈ បាទ!

ប្រពន្ធៈ ហើយយើងអត់អញ្ចឹងយើងមិនសូវហ៊ាននៅក្បែរគេដែរនិង។

កៈ បាទ!

ប្រពន្ធៈ ចាំ!
ព្រោះអីសម័យឥឡូវនិងគេរាប់តែអ្នកមានទេហើយពេលខ្លះគេឃើញអញ្ចឹងទៅគេហៅមុនខ្ញុំទៅនិយាយរកគេអញ្ចឹងណាស់។

ក៖ បាទ!

ប្រពន្ធ៖ ហើយពេលខ្លះគេមានអញ្ចឹងគេអត់ហៅទេពួកម៉ាក់ខ្លះនិងហើយគេឃើញគេចេះតែហៅយើងដែរនៅណាស់។

ក៖ បាទ!

ប្រពន្ធ៖ ហើយយើងអត់អញ្ចឹងយើងអត់ហ៊ានទៅហៅគេមុនទេ។

ក៖ បាទ! ហើយអញ្ចឹងបងមានស្គាល់ឈ្មោះមិត្តភក្តិបងជិតស្និតនិងទេបង?

ប្រពន្ធ៖ ខ្ញុំស្គាល់ពួកគេនិងតា។

ក៖ បាទ! ហើយអញ្ចឹងមានឈ្មោះអីគេខ្លះទៅបងស្រី?

ប្រពន្ធ៖ មានឈ្មោះថា ស្រី លក្ខណ៍។

ក៖ បាទ!ស្រី លក្ខណ៍។

ប្រពន្ធ៖ ស្រី មុំហើយគេនៅផ្ទះមុខផ្ទះអ៊ុំខ្ញុំនិង។

ក៖ បាទ!

ប្រពន្ធ៖ ប៉ូ លើន ប៉ូ ឡា ហើយចិន្តា ស្រីតុក ស្រីអូន មានច្រើនស៊ី នួនហើយគ្រាន់តែស៊ីនួនគេបានប្រពន្ធគេធ្វើប៉ូលិស។

ក៖ បាទ! គេបានប្តីគេធ្វើប៉ូលិសបង។

ប្រពន្ធ៖ អត់ទេគេនិងប្រុសទេគេបានប្រពន្ធធ្វើប៉ូលិស។

ក៖ បាទ! អញ្ចឹងគាត់និងប្រុសទេបងស្រី?

ប្រពន្ធ៖ ចា៎! ហើយគេធ្វើប៉ូលិស។

ក៖ បាទ!

ប្រពន្ធ៖ ចា៎!

ក៖ ហើយអញ្ចឹងបងមានមិត្តភក្តីប្រុសទៀតបងស្រី?

ប្រពន្ធ៖ ចាំ!
ខ្ញុំមានតាមិត្តភក្តិប្រុសនិងកាលនិងវាអត់ដូចឥឡូវអញ្ចឹងណាស់ឥឡូវអាយុ១២ទៅ១៣ឆ្នាំចេះមានស្នេហាហើយនិង។

ក៖ បាទ!

ប្រពន្ធ៖ ហើយបើកាលនិងអាយុ១២ទៅ១៣ឆ្នាំនៅឡូតនៅជិះកន្លានៅឡើយនិង។

ក៖ បាទ! នៅជិះកខ្ញុំនៅឡើយនិងបងស្រី។

ប្រពន្ធ៖ ចាំ! ហើយឥឡូវនិងគេសុទ្ធតែមានមុខរបរធំព្រោះអីម្តាយគេឪគេមានៗណាស់។

ក៖ បាទ!
ហើយគេឲ្យកូនគេរៀនបានចប់ហើយគេមានលុយឲ្យកូនគេមានមុខរបររកស៊ីអញ្ចឹងទៅបងស្រីព្រោះអីម្តាយឪពុកគេអ្នកមានណោះបងស្រី។

ប្រពន្ធ៖ ចាំ! គេមានមុខរបររកស៊ីហើយគេមានលុយឲ្យកូនគេរៀនដល់ចប់អញ្ចឹងណាស់។

ក៖ បាទ!

ប្រពន្ធ៖ ចាំ!

ក៖ បាទ!
ហើយអញ្ចឹងបងបើក្រៅពីភាសាខ្មែរវិញបងតើបងមានចេះភាសាបរទេសទេបងស្រីដូចជាភាសាអង់គ្លេស បារាំង ថៃ វៀតណាមទេបងស្រី?

ប្រពន្ធ៖ អត់សោះ។

ក៖ បាទ!

ប្រពន្ធ៖ ចាំ! បើនិយាយរួមនិងខ្ញុំអត់ចេះតែម្តងនិងម៉ង។

ក៖ បាទ! តែបងថាបងចេះបានតិចដែរតែយើងចេះស្ទើបងស្រី។

ប្រពន្ធ៖ ចាំ! ពេលខ្លះចេះស្ទើធ្វើភ្លើលម៉ងទៅណាស់។

ក៖ បាទ!

ប្រពន្ធ៖ បើអង់គ្លេសរៀនដែរតែអត់ចេះ។

កៈ បាទ! ហើយអញ្ជឹងបងមានចាំសាច់រឿងជាមួយមិត្តភក្តិបងថាមានធ្លាប់ទៅដើរលេងជាមួយគ្នាអត់បងស្រី?

ប្រពន្ធៈ ចាំ! ខ្ញុំធ្លាប់តាដូចថាកាលនៅរៀនអញ្ចឹងទៅណាត់គ្នាធ្វើអីហូបអញ្ចឹងទៅណាស់។

កៈ បាទ!

ប្រពន្ធៈ ហើយពេលខ្លះនាំគ្នាធ្វើទឹកស្ករនៅពេលមានខែស្វាយអញ្ចឹងណាស់។

កៈ បាទ!

ប្រពន្ធៈ នាំគ្នាធ្វើបុកល្ហុង។

កៈ បាទ!

ប្រពន្ធៈ ហើយធ្វើស្វាយកាពិកអីអញ្ចឹងទៅណាស់។

កៈ បាទ!

ប្រពន្ធៈ ហើយនាំគ្នាសប្បាយជុំគ្នាអីអញ្ចឹងទៅណាស់ហើយមានការសើចលេងសប្បាយទាំងអស់គ្នាអញ្ចឹងទៅណាស់។

កៈ បាទ! អត់ដែលទៀតទេឥឡូវបង?

ប្រពន្ធៈ អត់ដែលទេឥឡូវអត់ដែលមានពួកម៉ាក់ទេឥឡូវគេហៅទៅដែលកម្មពិធីអីចឹងគេហៅទៅដែលតែខ្ញុំកំរទៅព្រោះអីយើងអត់ហើយយើងរវល់។

កៈ បាទ!យើងអត់យើងខំប្រឹង?

ប្រពន្ធៈ ចាំ!យើងមានពេលណាចូលដូចធ្វើការចឹងណាស់ត្បាញណាស់ដល់យើងអត់ធ្វើដូចថាយើងធ្វើការខ្លួនយើងមែនតែបើយើងអត់ខំប្រឹងក៏យើងអត់ដែលត្បាញនឹងណាស់ម៉ោង៦ព្រឹកយើងចូលចឹងទៅត្បាញបាន២ស្បូងបានយើងងូតទឹកលូបមុខចូលហូបបាយកករូតទៅផ្សារចឹងទៅមកវិញចាប់ផ្តើមធ្វើទៀតរហូតមកដល់ពេលម៉ោងបាយចេញទៅធ្វើម្ហូបទៅរូតចឹងចូលធ្វើរហូតដល់ម៉ោង៥ ៦ចឹងទៅបានចេញមកងូតទឹកអោយកូនចឹងណាស់ហាត់ៗណាស់។

កៈ បាទ!អ្នកមីងធ្វើនៅផ្ទះខ្លួនឯងស្រួលជាងទៅធ្វើអោយគេ?

ប្រពន្ធៈ
គ្រាន់តែនៅផ្ទះខ្លួនឯងគ្រាន់វាស្រួលចេះយើងចង់តំណោតៗទៅយើងវាធូរមួយថ្ងៃយើងអាច់ឈប់បានបើយើងធ្វើការអោយគេយើងទៅទាំងឈឺចឹងបានថាវាពិបាក។

កៈ បាទ!អ្នកមីង?

ប្រពន្ធៈ
រាល់ថ្ងៃប្អូនថ្លៃអោយទៅធ្វើការតែខ្ញុំអត់ទៅធ្វើបើខ្ញុំទៅវាចោលកូនបានអ្នកណាមើកូនណាមួយម្តាយខ្ញុំគាត់លើសឈាមយើងទៅណាចោលគាត់វាមិនបានទេហើយកូនចៅយើងនៅតូចៗណាស់អោយគាត់មើគាត់មើយើងទាំងពីតូចហើយពិបាកហើយយើងអោយគាត់មើកូនយើងទៀតវាពិបាកចឹង។

កៈ បាទ!អ្នកមីងគិតច្រើន?

ប្រពន្ធៈ គិតច្រើនមិចអូនបើមិនគិតមិច។

កៈ បាទ!អ្នកខ្លះគេមិនគិតចឹងដូចអ្នកមីងទេ?

ប្រពន្ធៈ
មែនខ្ញុំថាអ្នកខ្លះគេមិនគិតទេគេថាទៅអោយតាឆ្ងាយចេញផុតពីផ្ទះរួតតែយើងចេញផុតពីផ្ទះមិចរួតមុននឹងយើងឈានជើងចេញពីផ្ទះទៅហូបការគេក៏ដោយទៅហូបមិនដែលស្រួលនឹងគេទេគេចេះតែថានៅរាំនៅអីសិតទៅខ្ញុំថាអត់ទេព្រោះអីប្រយាប់មកមើកូននៅផ្ទះព្រោះអីកូននៅតូចៗ។

កៈ បាទ!ត្រូវហើយអ្នកមីងព្រោះអីយើងមានកូនយើងមានគ្រួសារ?

ប្រពន្ធៈ
ចា៎!ព្រោះអីម៉ែគាត់រវលហើយមុននឹងយើងទៅហូបការហូបអីចឹងយើងត្រូវធ្វើម្ហូបធ្វើបាយព្រោះអីគេមកពីធ្វើការព្រលប់ម៉ែនឹងកូនផងអីផងកុំអោយគាត់ពិបាកគាត់។

កៈ
បាទ!ចឹងបងតាំងពីក្មេងរហូតមកដល់ធំនឹងតើបងមានដែលធ្លាប់ស៊ីឈ្នួលធ្វើស្រែធ្វើចំការអោយគេអត់?

ប្រពន្ធៈ ធ្លាប់ទៅធ្វើព្រៃខ្មែកព្រៃព្រែកអោយគេ។

កៈ បាទ!ចឹងកាលនឹងតើបានប៉ុន្មានដែលបង?

ប្រពន្ធ៖
អរកាលនឹងបានថោកនឹងពេលនឹងខ្ញុំនៅរៀនថ្ងៃអីចឹងទៅឈ្លាត់ទៅធ្វើអោយគេចឹងណាស់បានលុយរៀនព្រោះកាលនឹងឪពុកខ្ញុំនឹងគាត់ឈឺគាត់ស្លាប់មួយចំហៀងខ្លួនដល់ចឹងខ្ញុំរៀនអត់បានវែងបានត្រឹមថ្នាក់ទី៦នឹងឪពុកខ្ញុំធ្លាក់ខ្លួនឈឺនឹងខ្ញុំទៅស៊ីឈ្នួលគេស៊ីឈ្នួលធ្វើចំការចឹងទៅបានកាលនឹងបានមួយថ្ងៃ៨ពាន់នឹងយកមកចឹងទៅទិញថ្នាំអោយពុកខ្លះអីខ្លះចឹងណាស់ដូចថាឃើញយើងនឹងវាក្តៅពេកគាត់ឃើញអំបោះកាលនឹងអត់ទាន់មានសូត្រមានសូត្រតែយើងអត់ទាន់ចេះណាស់កាលនឹងឈ្លាត់មកពីរៀននឹងខ្ញុំអាយុ១២ឆ្នាំឈ្លាត់មកពីរៀនឈ្លាត់មកចូកគីអោយគេដល់ពេលខ្ញុំរៀនចេះដល់ពេលពុកខ្ញុំឈឺនឹងឈប់រៀនគាត់អោយឈប់រៀនត្បាញរហូតខ្ញុំត្បាញតាំងពីអាយុ១៥ឆ្នាំរហូតមកដល់៣០ឆ្នាំជាងត្បាញរហូតអស់មួយគីចូលមួយគីទៀតៗទៅរហូត។

ក៖ បាទ!នេះជាមុខរបររបស់យើងមួយ?

ប្រពន្ធ៖ ចាំ!នេះជាមុខរបរយើងនិយាយទៅតពីណាពីណើមកម៉ង។

ក៖ បាទ!ជាផ្នាំងបាយយើងនឹងណាស់?

ប្រពន្ធ៖
ចាំ!ចង់និយាយថាមនុស្សស្រីយើងចង់និយាយថាក្នុងស្រុកក្នុងភូមិយើងគឺមុខរបរប្រចាំត្រកូគឺត្បាញតែបើមនុស្សស្រីយើងនៅស្រុកនឹងអត់ចេះអានឹងមួយក៏ពិបាកដែលព្រោះយើងអត់មានទៅធ្វើការអស់មួយជីវិត្តបានទេត្រូវតែមានគ្រួសារមកធ្វើចឹងដើម្បីនៅក្នុងគ្រួសារ។

ក៖ បាទ!នៅមើលកូននៅមើលអីដែល?

ប្រពន្ធ៖
ចាំ!នៅមើលកូនព្រោះអីយើងមានកូនតូចយើងទៅធ្វើការនៅណាចេញយើងធ្វើអានឹងទៅគ្រាន់បានម្ហូបស៊ី។

ក៖ បាទ!ចឹងពេលណោះបងអត់ចាំថាបានប៉ុន្មានទេបង?

ប្រពន្ធ៖ បានអីគេ។

ក៖ បានប្រាក់កម្លៃបងណាស់?

ប្រពន្ធ៖ កាលនឹងស៊ីឈ្នួលគេបាន៧ ៨ពាន់មួយថ្ងៃ។

ក៖ បាទ!អរចឹងបានតា៧ ៨ ពាន់ក្នុងមួយថ្ងៃ?

ប្រពន្ធ៖ នឹងហើយបាន៧ ៨ពាន់។

កៈ បាទ!ធ្វើមួយទល់តែល្ងាចទៅ?

ប្រពន្ធៈ
ធ្វើមួយថ្ងៃទល់តែល្ងាចទៅដូចថាចូលធ្វើម៉ោង៧ម៉ោង៥ចេញមកនឹងទល់តែល្ងាចបាន៨៣ន់តែឥឡូវគេបានថ្លៃគេបាន១ម៉ឺនជាង២ម៉ឺន។

កៈ បាទ!ចឹងសព្វថ្ងៃនឹងតើបងមានកូនចំនួនប៉ុន្មានដែលបង?

ប្រពន្ធៈ ខ្ញុំសព្វថ្ងៃនឹងមានកូន២នាក់។

កៈ អរបាទ!កូន២នាក់?

ប្រពន្ធៈ ចាំ!ស្រីទាំង២នាក់។

កៈ បាទ!ស្រីទាំង២នាក់បាទចឹងរាល់ថ្ងៃនឹងគាត់នៅរៀនតាបង?

ប្រពន្ធៈ កូននៅរៀនកូនបងអាយុ១០ឆ្នាំ។

កៈ បាទ!តើថ្នាក់ទីប៉ុន្មានដែលបង?

ប្រពន្ធៈ ថ្នាក់ទី៣។

កៈ អរថ្នាក់ទី៣ហើយចុះពៅគេតើថ្នាក់ទីប៉ុន្មានដែល?

ប្រពន្ធៈ ពៅគេទុបតែ២ខួបទេ។

កៈ អរទុបតែកើតដែលនឹង?

ប្រពន្ធៈ នឹងហើយទុបតែ២ខួប។

កៈ
បាទ!ចឹងបងតាំងពីក្មេងរហូតមកដល់ធំតើបងមានការផ្លាស់ប្តូរអ្វីខ្លះដែលបងតាំងពីកម្មេងរហូតមកដល់ធំណាស់ហើយតាំងពីមានគ្រួសាររហូតមកដល់មានកូនចឹងណាស់តើបងមានការផ្លាស់ប្តូរអ្វីខ្លះមានការជួបឧបសគ្គច្រើនទេបង?

ប្រពន្ធៈ
មានច្រើនដូចថាយើងដូចថាយើងពីមុនមកពុកឈឺចឹងយើងអត់ចឹងយើងប្រឹងរកទាំងក្មេងចឹងណាស់។

កៈ បាទ!

ប្រពន្ធ៖
ហើយមកបងៗប្រពន្ធមុនៗនឹងគាត់មានគ្រួសារអស់ហើយនៅខ្ញុំប្អូនតូចៗទៅធ្វើការរោងចក្រកាលនឹងខ្ញុំអាយុ១៧ឆ្នាំ។

ក៖ បាទ!ចឹងលោកឪពុករបស់បងមានប្រពន្ធទល់តែពីរ?

ប្រពន្ធ៖
ប្រពន្ធពីរតែប្រពន្ធមុនគាត់ស្លាប់តែកូនធំៗកូនតូចៗកូននៅពិននឹងម៉ែខ្ញុំគាត់ការមកគាត់ចិញ្ចឹមរហូតដល់មានខ្ញុំទៀតចឹងឥឡូវបងខ្ញុំគាត់ធំៗគាត់ធ្វើផ្ទះអស់ហើយនៅមិខនឹងណាស់ដែលយើងមើលទៅឃើញនឹង។

ក៖ អរបាទ!

ប្រពន្ធ៖
ចា៎!គេបែកគ្រួសារអស់ហើយពុកខ្ញុំគាត់ឈឺឈឺទៅមិនយើងនឹងកូនក្រោយនឹងធំជាងគេអាយុ១៧ ១៨ឆ្នាំទៅធ្វើការរោងចក្រដូចថាឪពុកអត់ចឹងយើងត្រូវប្រឹងចឹងណាស់។

ក៖ បាទ!

ប្រពន្ធ៖
និយាយទៅគ្មានពេលសំរាកទេនិយាយទៅចំពាក់គេចំពាក់លុយអង្ការព្រោះអីយើងត្រូវការរកលុយនឹងមកមើលពុកផងអីផងហើយយើងអត់ប្អូនរៀនអទ់ទាន់មាននាក់ណាចេះធ្វើអីទេចឹងយើងត្រូវចេះខ្វាស់ខាតយើងចេះតែយកមកធ្វើនេះធ្វើនោះទៅយើងខ្វាស់ខាតអីចឹងណាស់។

ក៖ បាទ!ចឹងតើឪពុករបស់បងតើគាត់មានឈ្មោះអ្វីដែលបង?

ប្រពន្ធ៖ គាត់មានឈ្មោះ សេក ថុង។

ក៖ បាទ!គាត់ឈ្មោះ សេក ថុង?

ប្រពន្ធ៖ ចា៎!

ក៖ ចឹងអ្នកម្ដាយវិញបងតើគាត់ឈ្មោះអីគេដែលបង?

ប្រពន្ធ៖ ម្ដាយខ្ញុំគាត់ឈ្មោះ ថេង យង ។

ក៖ ថេង យង ?

ប្រពន្ធ៖
ចាំ!គាត់ស្លាប់យូរហើយគាត់ស្លាប់មួយចំហៀងខ្លួនគាត់លើសឈាមគាត់ស្លាប់មួយចំហៀងខ្លួន។

ក៖ បាទ!ចឹងគាត់ស្លាប់បានប៉ុន្មានឆ្នាំហើយបង?

ប្រពន្ធ៖ ឪពុកខ្ញុំគាត់ស្លាប់បាន១៣ឆ្នាំហើយ។

ក៖ អរនៅពេលនឹងគាត់ស្លាប់នឹងតើគាត់មានអាយុប៉ុន្មានដែលបង?

ប្រពន្ធ៖ ការនឹងគាត់ស្លាប់នឹងគាត់មានអាយុ៣៤៧ឆ្នាំ។

ក៖ ៣៧បង?

ប្រពន្ធ៖ ចាំ!ឥឡូវមកដល់ឥឡូវទល់ឥឡូវគាត់ឆ្នាំកោ។

ក៖ អរគាត់ឆ្នាំកោបង?

ប្រពន្ធ៖ ចាំ!

ក៖ បាទ!ចឹងបងជួបនៅឧបសគ្គច្រើនណាស់តាំងពីក្មេងមក?

ប្រពន្ធ៖
និយាយទៅមកដល់ឥឡូវក៏នៅពិបាកដែលតែគ្រាន់តែយើងពិបាកមានគ្រួសារមានបងប្អូនធំៗគេរកជួយទុបមកបើពីមុនចប់ហើយ។

ក៖ បាទ!ចឹងតើបងបញអូនបងសាក្រោយនេះតើមានប៉ុន្មាននាក់ដែលបង?

ប្រពន្ធ៖ មាន៤នាក់។

ក៖ អរបាទ!មាន៤នាក់?

ប្រពន្ធ៖ ស្រីខ្ញុំមួយប្រុស៤នាក់។

ក៖ អរចឹងតើបងកូនទីប៉ុន្មានដែលបង?

ប្រពន្ធ៖ ខ្ញុំកូនបើគិតជាកូនម៉ែខ្ញុំក្រោយខ្ញុំកូនបងគេ។

ក៖
បាទ!អរបងបើម្ដាយក្រោយគេបងជាកូនបងគេបាទចឹងបងបើម្ដាយបងក្រោយនឹងតើបងមានបងប្អូនប៉ុន្មាននាក់ដែលបង?

ប្រពន្ធ៖ បងប្អូន៥នាក់បងប្អូនបង្កើត៥នាក់។

ក៖ អរចឹងបើម្ដាយមុនបងតើប៉ុន្មាននាក់ដែលបង?

ប្រពន្ធ៖ ម្ដាយមុន៥នាក់ដែល។

ក៖ អរម្ដាយមុន៥នាក់ដែល?

ប្រពន្ធ៖ ចាំ!តែអត់គិតទេ។

ក៖ បាទ!ចឹងតើបងមាននៅចាំឈ្មោះគាត់ទេបង?

ប្រពន្ធ៖ បងគេឈ្មោះ ថុង ថា បងទី២ឈ្មោះ ថុង ថើន បងទី៣ឈ្មោះ ថុង ថន បងទី៤ឈ្មោះ ថុង ថាំង មកខ្ញុំក្រោយ ថុង យៀត ថុង បៀត ថុង រ៉ែក ថុង សីហា។

ក៖ បាទ!ចឹងបងបើនិយាយពីមុខម្ហូបវិញតើបងចូលចិត្តមុខម្ហូបមួយណាជាងគេដែលបង?

ប្រពន្ធ៖ ខ្ញុំម្ហូបខ្ញុំចូលចិត្តឆាគ្រឿង។

ក៖ អរឆាគ្រឿងបងចឹងបើប្រហើល សម្លក ម្ជូរគ្រឿង អីបងអត់ចូលចិត្តទេបង?

ប្រពន្ធ៖
ខ្ញុំចូលចិត្តដែលតែគ្រាន់ថាយើងនិយាយទៅយើងចំណាង់ចំណូររបស់យើងម៉ងបើខ្ញុំចូលចិត្តគឺឆាគ្រឿងចឹងទៅឆាកង្កែបចឹងទៅ។

ក៖ បាទ!ខ្ញុំចូលចិត្តដែលឆាកង្កែបលេខមួយម៉ង?

ប្រពន្ធ៖
បើមួយទៀតខ្ញុំចូលចិត្តជាងគេគឺប្រហុកចិញ្ច្រាមចូលចិត្តនិយាយទៅសុទ្ធតែចូលចិត្តទាំងអស់នឹង។

ក៖
បាទ!បើខ្ញុំវិញប្រហុកចិញ្ច្រាមប្រហុកលឹងអីនឹងខ្ញុំចូលចិត្តណាស់បាទចឹងបងបើនិយាយពីល្បែងប្រជាប្រិយវិញតើបងចូលចិត្តលេងល្បែងអ្វីជាងគេដែលដូចជា ចោលឈូង បោះអង្គុញ ទាញព្រាត់ លាក់កន្សែង លេងខ្លូង អីចឹងណាស់បងតើបងចូលចិត្តលេងមួយណាដែលបង?

ប្រពន្ធ៖
អានឹងខ្ញុំចូលចិត្តជាធម្មតាតែឥឡូវដូចថាយើងមានគ្រួសារយើងអត់លេងទេកាលយើងនៅ

ពីក្មេងៗអីនឹងចូលឆ្នាំអីចឹងនៅសល់៩ ១០ ២០ថ្ងៃចូលឆ្នាំយើងនាំគ្នាលេងហើយលេងខ្លងខ្សែដណ្ដើមផ្កាអីចឹងទៅអានឹងលេងលាក់កន្សែងអីនឹងលេងតែឥឡូវយើងវាធំៗអស់ទៅលែងលេងហើយតែក្មេងៗជំនាន់ក្រោយគេនៅលេង។

កៈ
បាទ!នៅពេលបងនៅក្មេងទៅវត្តអីតើពេលនឹងបងមានបានឃើញមានកំលោះៗគេចាប់អារម្មណ៍លើបងទេបងមានច្រើនតែបងអត់យកមកយកបងប្រុស?

ប្រពន្ធៈ អត់ទេខ្ញុំអាណិតគាត់។

កៈ បាទ!អាណិតគាត់បងគាត់ជាអ្នកនៅក្នុងភូមិគាត់ស្លូតដែល?

ប្រពន្ធៈ
នឹងហើយគាត់ស្លូតណាមួយយើងមិនស្រលាញ់លើរូបសម្បត្តិស្អាត់ទេជូនការដូចថាគ្រួសារយើងអត់យើងមិនបានគេដូចថាលោតពីយើងក៏វាមិនកើតហើយណាមួយយើងស្រវាតយកធន់ធានដូចគ្នាយើងអត់ដឹងក្រមានក៏អត់ដល់ពេលយើងស្រវាយកមានចឹងទៅយើងអ្នកក្រចឹងណាស់យើងអត់មានអ្នកហឺហាអីទេហើយចុះបេះគាត់ស្រលាញ់យើងគេជាអ្នកដែលរៀនបានច្រើនហើយគ្រួសារគេគ្រាន់បើដល់ពេលយើងស្រលាញ់គ្នាយើងបានតាទឹកភ្នែកធម្មតាទេ។

កៈ បាទ!យើងសប្បាយតាកាយតែយើងនឿយចិត្ត?

ប្រពន្ធៈ
ដូចថាយើងយកប្ដីអោយស្រុកចិត្តវាមិនស្រុកចិត្តទេវានៅតែពិបាកចិត្តដដែលនឹងហើយធម្មតាបើមនុស្សគេស្អាតសម័យឥឡូវគេត្រូវការមានស្រីតាយើងអត់ស្អាតអត់ពិបាកចិត្តអត់ដេកយំ។

កៈ បាទ!អត់ដេកយំ។

ប្រពន្ធៈ សម័យឥឡូវខ្ញុំដឹង។

កៈ បាទ!ចឹងសម័យឥឡូវគេស្អាតច្រើន?

ប្រពន្ធៈ គេចូលចិត្តស្អាតតែសុទ្ធតែគីមី។

កៈ អរបាទ!ចឹងបើនិយាយពីបទចម្រៀងវិញតើបងចូលចិត្តទេបងចម្រៀងរាំអីណាស់បង?

ប្រពន្ធៈ រាំខ្ញុំចូលចិត្ត។

កៈ បាទ!រាំបងចូលចិត្តចឹងច្រៀងបងអត់ចូលចិត្តបង?

ប្រពន្ធ៖ ច្រៀងក៏ខ្ញុំចូលចិត្តខ្ញុំច្រៀងរាល់អាទិត្យនឹងបាស់ខ្ញុំមានច្រៀងទៅ។

កៈ អរបាទ!បងមានបាស់?

ប្រពន្ធ៖
យើងច្រៀងលំហែលខួលក្បាលទៅមួយអាទិត្យច្រៀងក្រោមដើមឈើទៅជាមួយប្អូនបងថ្លៃតិចតួចទៅធ្វើម្ហូមញុំាជុំគ្នាចឹងទៅ។

កៈ បាទ!ញុំាអីតិចតួចអញ្ចឹងទៅបងស្រី?

ប្រពន្ធ៖ ចា៎! ញុំាអីជាមួយគ្នាតិចតួចអញ្ចឹងណាស់។

កៈ បាទ! ហើយអញ្ចឹងមានការសប្បាយនៅជាមួយគ្រួសារអញ្ចឹងទៅណាស់។

ប្រពន្ធ៖ ចា៎! ជួបជុំគ្នានៅក្រោមដើមជម្ពុនិងទៅណាស់។

កៈ បាទ!

ប្រពន្ធ៖
ហើយដាក់បាសមួយនិងទៅហើយចែកគ្នាច្រៀងទៅច្រៀងខុសខ្លះចេះតែច្រៀងទៅណាស់។

កៈ បាទ!

ប្រពន្ធ៖ ហើយនាំគ្នាច្រៀងសើចៗទៅណាស់។

កៈ បាទ!

ប្រពន្ធ៖ ហើយនាំគ្នាទៅជាលក្ខណៈគ្រួសារណាស់។

កៈ បាទ!

ប្រពន្ធ៖
ហើយដូចថាខ្ញុំមានការលំបាកមែនតែយើងត្រូវមានសប្បាយហើយលំហែខួរក្បាលដែរ។

កៈ បាទ!

ប្រពន្ធ៖
ហើយខ្ញុំគិតថាយើងស្មុគ្រហើយអ្នកខ្លះគេថាមានការលំបាកគេទៅសម្លាប់ខ្លួនហើយខ្ញុំអត់គិតអញ្ចឹងទេបើនិយាយពីសាច់ពិបាកនិងខ្ញុំពិបាកណាស់តែខ្ញុំអត់គិតអញ្ចឹងទេ។

ក៖ បាទ!

ប្រពន្ធ៖ ហើយខ្ញុំគិតថាខ្ញុំមានម្ដាយចាស់។

ក៖ បាទ! បើពិបាកត្រូវតែតស៊ូបងស្រី?

ប្រពន្ធ៖ ចាំ!
ហើយខ្ញុំពិបាកហើយខ្ញុំថាខែនិងខ្ញុំអត់អញ្ចឹងណាស់ហើយអត់លុយបង់អង្គការអញ្ចឹងណាស់ខ្ញុំរឹតតែប្រឹង។

ក៖ បាទ!

ប្រពន្ធ៖ វាគ្រាន់ថាយើងខំប្រឹងរហូតដល់គុបប្រលឹបអញ្ចឹងទៅ។

ក៖ បាទ!

ប្រពន្ធ៖ ចាំ!
ហើយបើយើងនិងតែថាពិបាកណាស់យកទៅផឹកស្រាហើយពិបាកទៅដេកគិតអានិងរឹកតែពិបាកវិញ។ហើយទោះថាយើងពិបាកប៉ុណ្ណាក៏ដោយមានការសប្បាយខ្លះទៅដូចថាកុំឲ្យយើងនិងមានការស្ទេសអញ្ចឹងណាស់។

ក៖ បាទ!

ប្រពន្ធ៖ ហើយបើខួរក្បាលយើងបើយើងនិងគិតស្ទេសមនុស្សយើងនិងមានការគិតផ្សេង។

ក៖ បាទ!

ប្រពន្ធ៖ ហើយដូចរបៀបថាគិតរឿងអីផ្សេងៗណាស់។

ក៖ បាទ!

ប្រពន្ធ៖
តែខ្ញុំអត់ទេហើយបើខ្ញុំអត់ខ្ញុំស៊ូហើយថ្ងៃនិងខ្ញុំគិតហើយស្អែងឡើងមានរឿងចាំគិតទៀត។

ក៖ បាទ!

ប្រពន្ធ៖ ហើយដូចគេថាជីវិតមនុស្សមានរូបមានទុកហើយ។

ក៖ បាទ!

ប្រពន្ធ៖ ហើយវាដើរទន្ទឹមគ្នានិង។

ក៖ បាទ!

ប្រពន្ធ៖ ហើយយើងនៅតែអង្គុយគិតថាថ្ងៃនិងអញអត់ហើយអញពិបាកចិត្តណាស់អញ។

ក៖ បាទ!

ប្រពន្ធ៖
ហើយវាគ្មានបានអីហើយខ្ញុំគិតថាថ្ងៃនិងខ្ញុំបានមួយថ្ងៃហើយខ្ញុំគិតហើយស្អែកឡើងចាំគិតទៀត។

ក៖ បាទ! បងស្រីគិតអញ្ចឹងត្រូវបងស្រី?

ប្រពន្ធ៖ ចាំ! ហើយខ្ញុំស្អែកឡើងចាំគិតទៀតហើយជីវិតមនុស្សអត់អ្នកណាខុសគ្នាទេ។

ក៖ បាទ!

ប្រពន្ធ៖
ហើយគេថាអញ្ចេកមើលទៅគេមានណាស់ហើយខ្ញុំសប្បាយចិត្តគេមានដៃរទ្រព្យហើយតែក្នុងចិត្តគេយើងអតដឹងទេ។

ក៖ បាទ!

ប្រពន្ធ៖ ចាំ!
ហើយអញ្ចឹងបានពាក្យចាស់និយាយអត់ខុសទេថាអុចចង្កៀងផ្ទះអ្នកណាភ្លឺផ្ទះអ្នកនិង។

ក៖ បាទ!

ប្រពន្ធ៖
ជួនកាលគេថាអញ្ចេកមានមុខរបរអីបានជាដល់ថ្នាក់ជំពាក់អង្គការហើយយើងអត់ដឹងថានៅក្នុងគ្រួសារគេនិងមានការលំបាកនិងរបៀបមិចអញ្ចឹងណាស់។

ក៖ បាទ!

ប្រពន្ធ៖
ហើយធម្មតាមនុស្សយើងអត់សុទ្ធចិត្តដេកអត់ហើយប្អូនប្ដីទៅធ្វើការសុទ្ធអត់ហើយទៅយើងមិនទៅជឿលបុលគេ។

ក៖ បាទ!

ប្រពន្ធ៖ ហើយកូនខ្ញុំមានអីរកកើត។

ក៖ បាទ!

ប្រពន្ធ៖ ហើយឪពុកម្ដាយគាត់ឈឺហើយអញ្ចឹងចេះតែជឿលគេជំពាក់គេអញ្ចឹងហើយ។

ក៖ បាទ!

ប្រពន្ធ៖ ហើយតែយើងនៅតែស្ងៀមនៅតែថាយើងអត់យើងប្រឹងរកសងគេ។

ក៖ បាទ!

ប្រពន្ធ៖ ហើយតែបើយើងអត់ហើយយើងទៅប៉ោឡេដើរផឹកក៏វាពិបាកដែរ។

ក៖ បាទ! បងស្រី?

ប្រពន្ធ៖ ហើយដូចថាយើងខ្ញុំលុយអញ្ចឹង។

ក៖ បាទ!

ប្រពន្ធ៖
ហើយគេមើលមកអត់ខំប្រឹងដើរសប្បាយប្រឹងហឺហាហើយតែអត់ឲ្យលុយខ្ញុំតែបើយើងអត់យើងប្រឹងរកអញ្ចឹងបើហាខ្ញុំគេនិងគេឲ្យយើងណាហើយគេថាគ្នាអត់មែនតែគ្នាប្រឹងរក។

ក៖ បាទ!
ហើយអញ្ចឹងបងបើនិយាយពីបងប្អូនជីដូនមួយជីទួមួយអីមាននរណាគេគាត់ចេះលេងឧបករណ៍តន្ត្រីដូចជាលេង ស្គរ ទ្រ ហ្គីតា ព្យាណូហើយនិង ខ្លុយ ចាប៉ីទេបងស្រី?

ប្រពន្ធ៖ ចាំ!
មានព្រោះអីឪពុកខ្ញុំនិងគាត់អ្នកលេងភ្លេងការម៉េង។តែអត់មានកូនស្នងព្រោះអីគាត់ជាអ្នកលេងស្ទើតម៉ងឥឡូវតាខេគាត់នៅលើផ្ទះនៅរាល់ថ្ងៃនិងតាតែអត់មានអ្នកចេះលេងហើយគ្រាន់ថាគាត់ឈឺទៅគាត់អត់បានបង្រៀនកូនណាស់។

ក៖ បាទ!

ប្រពន្ធ៖ ព្រោះអីកូនគាត់នៅតូចៗហើយគាត់រៀបបង្រៀនទៅគាត់ឈឺទៅ។

ក៖ បាទ!

ប្រពន្ធ៖ ហើយអញ្ចឹងទៅអត់មានអ្នកស្នងអញ្ចឹងណាស់។

ក៖ បាទ! ហើយអញ្ចឹងអត់មានអ្នកស្នងបងស្រី?

ប្រពន្ធ៖ ចាំ! ហើយអញ្ចឹងទៅអត់ពីឪពុកខ្ញុំទៅអត់មានអ្នកចេះលេងផងនិង។

ក៖ បាទ! ហើយអញ្ចឹងបងបើនិយាយពីលក្ខណៈ
ផ្ទះរបស់បងកាលដែរនៅជាមួយឪពុកម្តាយរបស់បងមានលក្ខណៈបែបណាដែរបង?

ប្រពន្ធ៖
កាលផ្ទះខ្ញុំហោសពីមុនផ្ទះខ្ញុំនៅខាងមុខទេតែតូចហើយថ្លុះដំបូលថ្លុះជញ្ជាំងអីអញ្ចឹងណាស់
។

ក៖ បាទ! ហើយអញ្ចឹងបងផ្ទះបងដំបូលសង្ក័សី។

ប្រពន្ធ៖ ចាំ!

ក៖ បាទ! ហើយអញ្ចឹងជញ្ជាំងអីគេបងស្រី?

ប្រពន្ធ៖ ជញ្ជាំងសង្ក័សីដែរនិង។

ក៖ បាទ! ហើយអញ្ចឹងជញ្ជាំងសង្ក័សីដែរបងស្រីហើយអញ្ចឹងរណាបនិងអីគេដែរបងស្រី?

ប្រពន្ធ៖ ហើយបើអាណាបនិងមានក្តាខ្លះអីខ្លះទៅរណាបនិងធម្មតានិងអាស្សីនិង។

ក៖ បាទ! ហើយអញ្ចឹងបងឪពុកបងធ្វើផ្ទាល់ឬក៏គាត់ជួលគេបងស្រី?

ប្រពន្ធ៖ អត់ទេគាត់ធ្វើផ្ទាល់ទេខ្ញុំទេ។

ក៖ បាទ! ហើយអញ្ចឹងផ្ទះនិងបងស្រីអ្នកធ្វើផ្ទាល់បងស្រី?

ប្រពន្ធ៖ ចាំ!

ក៖ បាទ! ហើយអញ្ចឹងបងស្រីអ្នកធ្វើផ្ទាល់។

ប្រពន្ធ៖ ចាំ! ហើយយើងមានខ្លះហើយខ្ចីលុយអង្គការខ្លះទៅណាស់។

ក៖ បាទ!

ប្រពន្ធ៖
ហើយយកមកផ្គប់ផ្គង់គ្រួសារព្រោះអីផ្ទះយើងនិងលិចនិងហើយយើងត្រូវតែធ្វើអញ្ចឹងទៅណាស់។

ក៖ បាទ!
ហើយអញ្ចឹងបងស្រីបើនិយាយការត្បាញនិងបងចេះខ្លួនឯងឬបងទៅរៀនបងស្រី?

ប្រពន្ធ៖ អត់ចេះខ្លួនឯងទេទៅរៀនតាមគេ។

ក៖ បាទ! ហើយអញ្ចឹងបងរៀនតាមគេបងស្រី។

ប្រពន្ធ៖ ហើយគ្រួសារខ្ញុំអត់មានអ្នកចេះទេ។

ក៖ បាទ!

ប្រពន្ធ៖ ចាំ!
ហើយបើគ្រួសារខ្ញុំបើពុកខ្ញុំនៅនេះគាត់ទៅលេងភ្លេងទៅហើយទៅរៀយមង់ទៅហើយទៅពូកខ្ញុំចិញ្ចឹមជ្រូកហើយអញ្ចឹងអត់មានចេះទេប៉ុន្តែយើងឆ្លៀតថាចេញពីរៀនមកហើយយើងឆ្លៀតទៅចូលផ្ទះអ្នកដែរគេធ្វើអញ្ចឹងណាស់។

ក៖ បាទ! ហើយអញ្ចឹងបងឈរមើលគេបងស្រី?

ប្រពន្ធ៖
អត់ឈរមើលគេទេហើយគេឃើញយើងនិងចង់អញ្ចឹងគេឲ្យយើងចូលត្បាញនិងទៅណាស់ហើយដូចថាគេឆ្លៀតចូលហូបបាយយើងឆ្លៀតចូលរបស់គេទៅណាស់។

ក៖ បាទ!

ប្រពន្ធ៖ ហើយយើងចូលយូរៗទៅយើងចេះអញ្ចឹងណាស់។

ក៖ បាទ!

ប្រពន្ធ៖ ហើយដល់ពេលចេះហើយខ្ញុំអាចធ្វើខ្លួនឯងកើត។

ក៖ បាទ!

ប្រពន្ធ៖ ហើយនិងគេហៅថាតំម្រេសបានយើងចំនេញបានគេណាស់។

កៈ បាទ! ហើយអញ្ចឹងបងស្រីក្រៅពីនិងបងអត់មានស្មុងអីពីគាត់ទេបងណោះ។

ប្រពន្ធៈ អត់មានទេ។

កៈ បាទ!
អត់មានទេ។ហើយអញ្ចឹងបងកាលពីបងនៅពេលបានចូលរៀនអញ្ចឹងណាស់ហើយបងមានក្ដីស្រមៃថាពេលរៀនចប់បងចង់ធ្វើជាគ្រូបង្រៀនហើយគ្រូពេទ្យហើយទាហាន ប៉ូលិសអីទេបងស្រី?

ប្រពន្ធៈ
ខ្ញុំចង់តាហើយកាលនៅតូចចង់ធ្វើហើយខ្ញុំចង់ចេះគ្រូហើយបើភាគច្រើនចង់ចេះសម្អាងការ។

កៈ បាទ! ហើយអញ្ចឹងបងចង់ចេះសម្អាងការបងស្រី។

ប្រពន្ធៈ នឹងហើយ។

កៈ បាទ!ហើយអញ្ចឹងអត់បានក្ដីស្រមៃហើយបានមកត្បាញអញ្ចឹងវិញបងស្រីណោះ។

ប្រពន្ធៈ ចា៎!បានមកត្បាញអញ្ចឹងវិញ។

កៈ បាទ!

ប្រពន្ធៈ ចា៎!
តែរាល់ថ្ងៃនិងមានអ្នកគេធ្វើសក់ទៅលើៗអញ្ចឹងគេធ្វើសក់អញ្ចឹងណាស់ហើយចេះហុចដំកៀបឲ្យអីអញ្ចឹងទៅណាស់។

កៈ បាទ!

ប្រពន្ធៈ
ហើយគ្រាន់តែផាត់មុខយើងចេះបានតិចតួចហើយយើងអត់អាចបានផាត់មុខគេបានទេ។

កៈ បាទ!

ប្រពន្ធៈ ហើយយើងចេះតែលួចគេអញ្ចឹងទៅ។

កៈ បាទ!

ប្រពន្ធៈ ហើយបើឲ្យយើងឆ្វងអត់បានទេអញ្ចឹងណាស់។

កៈ បាទ!

ប្រពន្ធៈ ចាំ! គ្រាន់តែយើងបានរៀនបានតិចៗហើយមនុស្សយើងចេះច្រើនក៏វាល្អដែរ។

កៈ បាទ!
ត្រូវហើយបងស្រី។ហើយអញ្ចឹងជាចុងក្រោយបងមានពាក្យអីចង់ផ្តែផ្តាំទៅកូនចៅបងជំនាន់ក្រោយថាឲ្យពួកគាត់ខិតខំប្រឹងរៀនអញ្ចឹងណាស់។

ប្រពន្ធៈ ចាំ!
ខ្ញុំមានតាហើយខ្ញុំចង់ផ្តាំថាជំនាន់ខ្ញុំវាអញ្ចេកអត់បានរៀនហើយ។ហើយខ្ញុំចង់ឲ្យកូនក្រោយនិងបានរៀនភាសាហើយក៏ឲ្យខ្មែរយើងបានច្រើនហើយរៀនភាសាបានច្រើនដែរអញ្ចឹងណាស់។ហើយសម័យឥឡូវតទៅមុខទៀតក៏វាអត់ត្រូវត្បាញនិងរហូតដែរ។

កៈ បាទ!

ប្រពន្ធៈ ហើយចំការអីក៏អត់មានកូនក្រោយនិងទៅធ្វើដែរ។

កៈ បាទ!

ប្រពន្ធៈ
ព្រោះអីគេខ្លាចក្តៅហើយអញ្ចឹងបើខ្លាចក្តៅនិងហើយគេបានទៅរៀនបានច្រើនហើយបើខ្លាចក្តៅហើយគេមានប្រាក់ខែច្រើន។

កៈ បាទ!

ប្រពន្ធៈ
ហើយគ្រាន់តែគេប្រើខួរក្បាលគេបានប្រាក់ខែច្រើនហើយយើងប្រឹងនៅហាលក្តៅៗអញ្ចឹងណាស់ហើយនៅក្នុងម្លប់ហើយបានលុយតិចទៀត។

កៈ បាទ!

ប្រពន្ធៈ
ហើយបើគេប្រឹងតែចំណេះគេនិងហើយនិងខួរក្បាលគេនិងគេអាចបានលុយរាបពាន់មួយខែៗ។

កៈ បាទ!ត្រូវហើយបងស្រី។

ប្រពន្ធៈ ចាំ!

កៈ ហើយអញ្ចឹងបើបងចង់ឲ្យគាត់ជៀសវាងអីគេបងស្រី?

ប្រពន្ធៈ ហើយបើចង់ឲ្យជៀសវាងជាងគេហេស។

កៈ បាទ!

ប្រពន្ធៈ និងស្រាហើយនិងគ្រឿងញៀននិងខ្លាំងទៀតគេទីបំផុត។

កៈ បាទ! ហើយនិងល្បែងស៊ីសងបងស្រី។

ប្រពន្ធៈ នឹងហើយ។

កៈ បាទ! ហើយនិងបងធំបងតូច។

ប្រពន្ធៈ រាល់ថ្ងៃនិងបានប្អូនរឿងអញ្ចឹងអត់ទេ។

កៈ បាទ!

ប្រពន្ធៈ ចាំ!
ខ្ញុំមានប្អូនពៅខ្ញុំមួយនិងអត់អីទេប្អូនពៅដេកនិងមិញនិងអត់ទេធ្វើការគ្រាន់ថាអញ្ចេកផឹកអី មានតិចតួចហើយគ្រាន់ថាមានបញ្ហាអីអត់មានទេ។

កៈ បាទ!

ប្រពន្ធៈ
ហើយគ្រាន់ថាយើងជៀសវាងនិងគ្រឿងញៀននិងហើយនិងស្រានិងហើយល្បែងនិងត្រូវ ហើយត្រូវតែជៀសវាងវាក៏ល្អដែរ។

កៈ បាទ! ហើយអញ្ចឹងបងមានពាក្យអីចុងក្រោយទេបងស្រី?

ប្រពន្ធៈ ចុងក្រោយនិងអត់ដឹងថាមានពាក្យអត់មានអីទេ។

កៈ បាទ! ហើយអញ្ចឹងបងមានតែប៉ុណ្ណឹងទេបងស្រី?

ប្រពន្ធៈ មានតែប៉ុណ្ណឹងទេ។

កៈ បាទ!
ហើយអញ្ចឹងជាចុងក្រោយខ្ញុំសូមអរគុណបងដែលបានញែកពេលវេលាដ៏មានតម្លៃមកកាន់ សាលា B Y U

យើងខ្ញុំអញ្ជឹងបងស្រីហើយអញ្ជឹងសូមជូនពរឲ្យបងមានសុខភាពល្អហើយការត្បាញការរកស៊ីរបស់បងចេះតែកាកកបទៅមុនអញ្ជឹងបងស្រី។

ប្រពន្ធ៖ សាធុក ។

ក៖ បាទ! ហើយអញ្ជឹងហើយសូមអ៊ុំស្រីមានសុខភាពល្អផងដែរអ៊ុំស្រី?

ម្ដាយ៖ ចាំ!

ក៖ ហើយអញ្ជឹងខ្ញុំសូមអនុញ្ញាតបងយកសម្លេងបងទៅឲ្យសាលាបងទេបងស្រី?

ប្រពន្ធ៖ អត់អីទេយកទៅប្រកាន់អីទេគ្រាន់តែសម្លេងនិង។

ក៖ បាទ! ហើយអញ្ជឹងសូមឲ្យថតរូបបងអញ្ជឹងបានអត់បង?

ប្រពន្ធ៖ បាទ! មានអី។

ក៖ ហើយអញ្ជឹងសូមអរគុណច្រើនបងស្រី។

ប្រពន្ធ៖ ចាំ!